# ព្រះរាជក្រម

នស/រកម/០៦១០/០១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យទៅក្រុមហ៊ុនខេមបូឌាន ត្រេនមីស៊ិន លីមីធីត ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

**ច្បាប់**
**ស្តីពី**
**ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល**
**នៃព្រះរាជាណាចក្រកម្ពុជា ឲ្យទៅក្រុមហ៊ុន**
**ខេមបូឌាន ទ្រែនមីសិន លីមីធីត**

**មាត្រា ១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុនខេមបូឌាន ទ្រែនមីសិន លីមីធីត ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ក្រុមហ៊ុនខេមបូឌាន ទ្រែនមីសិន លីមីធីត និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី រវាងអគ្គិសនីកម្ពុជា និង ក្រុមហ៊ុនខេមបូឌាន ទ្រែនមីសិន លីមីធីត ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១០ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៦១០.៥៤៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខៈ ៤៨៧ ច.ល

ហត្ថលេខា

គាត ឈន់

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ិនគេន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០១......សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១០

# លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ : **លោក** H'NG CHUN HSIANG
**ក្រុមហ៊ុន ខេមបូឌាន ទ្រែនស៊ីសិន លីមីធីត**

អាស័យដ្ឋាន: រោងចក្រអគ្គិសនីទី២, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែលើ, ខណ្ឌមានជ័យ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារ : 855 23 425 990

**យោង** :

(ក) សិទ្ធិប្រទាន លេខ ០៧ សប្រទ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (លិខិតសិទ្ធិប្រទាន ក្នុងឧបសម្ព័ន្ធ១) ។

(ខ) **កិច្ចព្រមព្រៀងអនុវត្តគម្រោង** (IA) ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល «ក្រ.ឧ.រ.ថ»** និង **ក្រុមហ៊ុន ខេមបូឌាន ទ្រែនស៊ីសិន លីមីធីត** (Cambodian Transmission Limited) **«ក្រុមហ៊ុន»** ។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ **«អ.ក»** ដែលបានចុះកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី (PTA) ជាមួយ **ក្រុមហ៊ុន** ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ។

(ឃ) **រាជរដ្ឋាភិបាលកម្ពុជា** បានយល់ព្រមផ្តល់ : (១)-ការធានាលើការទូទាត់ថ្លៃកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី សម្រាប់ការប្រើប្រាស់គម្រោង ១០០% (មួយរយភាគរយ) ក្នុងករណីដែល **អ.ក** មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់ថ្លៃទិញមធ្យោបាយគម្រោង ដោយបញ្ចប់កិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី និង/ឬកិច្ចព្រមព្រៀងអនុវត្តគម្រោង ក្នុងករណីដែល **ក្រុមហ៊ុន** មិនអាចដំណើរការអាជីវកម្មបាន ដោយហេតុកើតចេញពីព្រឹត្តិការណ៍ប្រធានសក្តិផ្នែកនយោបាយ ។

(ង) តាមការតម្រូវក្នុងផ្នែក ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង **រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «ក្រ.ស.ហ.វ»** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា **«អ្នកធានា»** បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដោយ **អ.ក/ក្រ.ឧ.រ.ថ** ស្របតាមកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី និងកិច្ចព្រមព្រៀងអនុវត្តគម្រោង ។

**ដូច្នេះ យើងខ្ញុំសូមធានា ថា:**

១. **អ្នកធានា** ធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យ **ក្រុមហ៊ុន** នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ **អ.ក/ក្រ.ឧ.រ.ថ** ឱ្យ **ក្រុមហ៊ុន** ស្របតាមកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី ដែល **អ.ក/ក្រ.ឧ.រ.ថ** ខកខានពុំបានទូទាត់អនុលោមតាមអាណត្តិ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី ។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យ **ក្រុមហ៊ុន** គ្រប់ពេលដោយ **ក្រ.ឧ.រ.ថ** ឬ **អ.ក** ស្របតាមកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង **ក្រ.ឧ.រ.ថ** ឬ **អ.ក** ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងតម្រូវការទូទាត់ពី**អ្នកធានា** **ក្រុមហ៊ុន**ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី **ក្រ.ឧ.រ.ថ** ឬ **អ.ក**។ ក្រោយរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយប័ត្រ ដូចមានចែងក្នុងផ្នែក ១១.១ នៃកិច្ចព្រមព្រៀងបញ្ចូនអគ្គិសនី ឬសំណើសុំទូទាត់ណាមួយពី **ក្រុមហ៊ុន** ទៅ **ក្រ.ឧ.រ.ថ** ឬ **អ.ក** ហើយត្រូវបានទទួលដោយ **ក្រ.ឧ.រ.ថ** ឬ **អ.ក** **ក្រុមហ៊ុន** អាចជូនដំណឹងទៅ **អ្នកធានា** ជាលាយលក្ខណ៍អក្សរ ថាការទូទាត់ដោយ **ក្រ.ឧ.រ.ថ** ឬ **អ.ក** បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពី **អ្នកធានា** ស្របតាមលិខិតធានានេះ ហើយ **អ្នកធានា** ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់ **អ្នកធានា** ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូកបី ៣% (បីភាគរយ) ។ ហើយពុំមានសំណើណាមួយ

ដែលធ្វើឡើងដោយ **ក្រុមហ៊ុន** ស្របតាមកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ **ក្រុមហ៊ុន** ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយប័ត្រ មិនបានទូទាត់ផ្សេងទៀត ។

ទឹកប្រាក់ទាំងអស់ ដែល **អ្នកធានា** ត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល **ក្រុមហ៊ុន** បានកំណត់ ជាដុល្លារអាមេរិកឱ្យ **ក្រុមហ៊ុន** ។

៤. រាល់ការធ្វើសំណើសុំទូទាត់ណាមួយ ដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬតាមរយៈបុគ្គល ដែលជាមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់ របស់ **ក្រុមហ៊ុន** នៅការិយាល័យរបស់ **អ្នកធានា** និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់ របស់ **ក្រុមហ៊ុន** ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា :

"យើងខ្ញុំ សូមបញ្ជាក់ថា :

(១) **ក្រុមហ៊ុន ខេមបូឌាន ខ្វែនមីស៊ិន លីមីធីត «ក្រុមហ៊ុន»** បានធ្វើសំណើទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **«អ្នកធានា»** ក្នុងចំនួនទឹកប្រាក់...................... {បញ្ចូលទឹកប្រាក់} ជាដុល្លារអាមេរិក ស្របតាមផ្នែក១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី ........ ខែ ......... ឆ្នាំ ......... រវាង **អ្នកធានា** និង **ក្រុមហ៊ុន** ។

(២) ចំនួនទឹកប្រាក់កំណត់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ (**ក្រ.ខ.ស.ហ** ឬ **អ.ក**) ស្របតាមកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ឬកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាង **ក្រុមហ៊ុន** និង **ក្រ.ខ.ស.ហ** ឬ **អ.ក** និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃជម្លោះ រវាង **ក្រ.ខ.ស.ហ/អ.ក** និង **ក្រុមហ៊ុន** ។

(៣) សំណើសុំទូទាត់ពី **ក្រ.ខ.ស.ហ/អ.ក** ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ ។

(៤) ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ **ក្រ.ខ.ស.ហ/អ.ក** រហូតដល់ថ្ងៃនេះ ។"

៥. **អ្នកធានា** សូមអះអាង និងធានា នៅថ្ងៃនេះថា :

**អ្នកធានា** មានសិទ្ធិពេញលេញ និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេត តាមអាណត្តិ និងបញ្ញត្តិ នៃលិខិតធានានេះ ។

លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ ដែល **អ្នកធានា** ត្រូវអនុវត្ត អនុលោមតាមអាណត្តិរបស់លិខិតធាននេះ ។ A